# ជំងឺអុតស្វា (Monkeypox)

## 1. តើអ្វីទៅជាជំងឺអុតស្វា?

ជំងឺអុតស្វាជាប្រភេទជំងឺកម្រមួយ ដែលបង្កឡើងដោយការឆ្លងមេរោគអុតស្វា។ ជំងឺនេះមិនមានកើតឡើងតាមធម្មជាតិនៅក្នុងសហរដ្ឋអាមេរិកនោះទេ។ ទោះជាយ៉ាងណាក៏ដោយ នាពេលថ្មីៗនេះ មានការរាយការណ៍អំពីករណីឆ្លងជាច្រើនក្នុងបណ្តាប្រទេសមួយចំនួន ដែលជាធម្មតាមិនធ្លាប់បានរាយការណ៍ថាមានករណីឆ្លងជំងឺអុតស្វាទេ ហើយក្នុងនោះក៏រួមមាន ខោនធី LA ផងដែរ។

## 2. តើជំងឺអុតស្វាឆ្លងតាមរបៀបណា?

ជំងឺអុតស្វារីករាលដាលនៅពេលដែលមនុស្សម្នាក់ប៉ះពាល់ជាមួយនឹងសត្វ ឬមនុស្សដែលមានមេរោគនោះ។ ជំងឺនេះក៏អាចរីករាលដាលតាមរយៈការប៉ះពាល់ទៅនឹងសារធាតុរាវក្នុងខ្លួននិងដំបៅអុតស្វា សម្ភារទាំងឡាយណាដែលបានប្រឡាក់ទៅនឹងសារធាតុរាវឬដំបៅ (សម្លៀកបំពាក់ កម្រាលពូក ឬស្រោមខ្នើយ ។ល។) ការរួមភេទ ឬក៏តាមរយៈការប៉ះពាល់ដោយផ្ទាល់ រយៈពេលវែងទៅនឹងតំណក់ទឹកតូចៗតាមផ្លូវដង្ហើម។ ការចម្លងអាចនឹងកើតមានឡើងក្នុងអំឡុងពេលរួមភេទ តាមរយៈការប៉ះពាល់ស្បែកនឹងស្បែក ហើយនិងការប៉ះពាល់ជិតស្និទ្ធដទៃទៀតផងដែរ។

## 3. តើសញ្ញានៃជំងឺអុតស្វាមានអ្វីខ្លះ?

សញ្ញាដំបូងៗអាចមានដូចជា គ្រុនក្តៅ ភាពល្ហិតល្ហៃ (ពិបាកក្នុងខ្លួន) ឈឺក្បាល ហើមកូនកណ្តុរ និងពេលខ្លះក្អក ឬឈឺបំពង់កផងដែរ។ រោគសញ្ញាផ្សេងទៀតមានដូចជា ឈឺសាច់ដុំ ចុកខ្នង គ្រុនរងា និងអស់កម្លាំង ហើយបន្ទាប់មកមានឡើងកន្ទួលរមាស់ ដែលធម្មតាចាប់ផ្តើមចេញនៅលើមុខ ហើយរាលដាលដល់ផ្នែកផ្សេងទៀតនៅលើដងខ្លួន។ ជំងឺនេះអាចនឹងបាត់ទៅវិញក្នុងរយៈពេលពី ពីរទៅបួន សប្តាហ៍។ ហើយមនុស្សមួយចំនួនគ្រាន់តែមានឡើងកន្ទួលរមាស់ និងពេលខ្លះមានហើមកូនកណ្តុរ ហើយពេលខ្លះមិនមាន ព្រមទាំងដែលអាចនឹងចេញនៅលើប្រដាប់ភេទ។

## 4. តើជំងឺនេះអាចព្យាបាលបានដោយរបៀបណា?

នាពេលបច្ចុប្បន្ន នៅមិនទាន់មានវិធីព្យាបាលជាក់លាក់សម្រាប់ជំងឺអុតស្វានៅឡើយទេ។ អាចនឹងមានការប្រើប្រាស់ថ្នាំពេទ្យ ដើម្បីសម្រាលរោគសញ្ញានៃជំងឺនេះ។ ចំពោះករណីមួយចំនួន អាចនឹងមានផ្តល់ជូនថ្នាំបង្ការ ដើម្បីទប់ស្កាត់ជំងឺនេះ បន្ទាប់ពីមានការប៉ះពាល់ទៅនឹងមេរោគក្នុងកម្រិតហានិភ័យខ្ពស់។

## 5. តើអ្នកអាចទប់ស្កាត់ជំងឺអុតស្វាបានដោយរបៀបណា?

ជំហានផ្សេងៗក្នុងការជួយទប់ស្កាត់ជំងឺអុតស្វា មានដូចជា៖

- ជៀសវាងការប៉ះពាល់ជាមួយនឹងសម្ភារដូចជាកម្រាលពូកឬស្រោមខ្នើយ និងសម្លៀកបំពាក់ ដែលធ្លាប់បានប៉ះពាល់ទៅនឹងសត្វដែលឈឺ ឬមនុស្សដែលបានឆ្លងមេរោគនេះ
- ជៀសវាងការប៉ះពាល់ជាមួយនឹងមនុស្សដែលមាន ឬអាចនឹងមានមេរោគនេះ
- ជៀសវាងការប៉ះពាល់ជាមួយនឹងសត្វដែលអាចនឹងមានមេរោគនេះ (ដូចជាសត្វដែលឈឺ ឬបានស្លាប់)
- លាងសម្អាតដៃជាមួយនឹងសាប៊ូនិងទឹក ឬប្រើប្រាស់ទឹកអនាម័យលាងដៃដែលមានជាតិអាល់កុល បន្ទាប់ពីបានប៉ះពាល់ទៅនឹងសត្វ ឬមនុស្សដែលឆ្លងជំងឺ។

នៅមិនទាន់មានវិធីជាក់លាក់ដែលទទួលបានការអនុម័ត សម្រាប់ព្យាបាលជំងឺអុតស្វានៅឡើយទេ ប៉ុន្តែអាចនឹងមានផ្តល់ជូនថ្នាំពេទ្យដើម្បីសម្រាលរោគសញ្ញា។ យ៉ាងណាមិញ ចំពោះស្ថានភាពមួយចំនួន មានថ្នាំបង្ការមួយប្រភេទដែលអាចប្រើប្រាស់សម្រាប់ទប់ស្កាត់ជំងឺអុតស្វាបាន អាស្រ័យទៅលើកម្រិតនៃការប៉ះពាល់ទៅនឹងមេរោគរបស់ពួកគេ។

## 6. តើជំងឺអុតស្វាពេលនេះរីករាលដាលដល់កម្រិតណាហើយ?

នាពេលឥឡូវនេះ មានការផ្ទុះឡើងនៃជំងឺអុតស្វា នៅតាមបណ្តាប្រទេសជាច្រើន ដែលក្នុងនោះមិនមានការពាក់ព័ន្ធជាមួយនឹងសត្វ ឬការធ្វើដំណើរទៅកន្លែងដែលធ្លាប់មានផ្ទុះជំងឺនេះនោះទេ។ តំបន់ជាច្រើននៅក្នុងសហរដ្ឋអាមេរិកបានកំណត់ថាមានករណីឆ្លង រួមមានទាំងករណីឆ្លងផ្សេងៗដែលបានបញ្ជាក់ថាមាននៅក្នុងរដ្ឋកាលីហ្វ័រញ៉ាផងដែរ។ នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles កំពុងតែពិនិត្យតាមដានស្ថានភាពនេះ និងផ្តល់ដំណឹងដល់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនានាឲ្យបង្កើនការប្រុងប្រយ័ត្ន ដែលទន្ទឹមនឹងនោះដែរ មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ក៏កំពុងតែតាមដានមើលករណីឆ្លងជាចង្កោមផងដែរ។ សម្រាប់បច្ចុប្បន្នភាពថ្មីៗបំផុតពាក់ព័ន្ធនឹងជំងឺអុតស្វានៅក្នុងខោនធី LA សូមចូលទៅកាន់គេហទំព័រ៖ ph.lacounty.gov/media/monkeypox/។



### ចំណុចសំខាន់ៗ៖

- ជំងឺអុតស្វា មិនងាយឆ្លងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទេ។
- នាពេលបច្ចុប្បន្ន នៅមិនទាន់មានវិធីជាក់លាក់ដែលទទួលបានការអនុម័ត សម្រាប់ព្យាបាលជំងឺអុតស្វានៅឡើយទេ ប៉ុន្តែអាចនឹងមានផ្តល់ជូនថ្នាំពេទ្យមួយចំនួនដើម្បីសម្រាលរោគសញ្ញានានា។
- ដើម្បីជួយទប់ស្កាត់ជំងឺអុតស្វា សូមជៀសវាងការប៉ះពាល់ជាមួយនឹងសត្វ ឬមនុស្ស ដែលអាចនឹងមានមេរោគ ហើយជៀសវាងការប៉ះពាល់ជាមួយនឹងសម្ភារដែលបានប៉ះពាល់ទៅនឹងសត្វ ឬមនុស្សដែលឈឺ និងអនុវត្តការថែរក្សាអនាម័យដៃឱ្យបានល្អ បន្ទាប់ពីបានប៉ះពាល់ជាមួយនឹងសត្វ ឬមនុស្សដែលឆ្លងជំងឺ។

### តើសាធារណជនអាចស្វែងរកព័ត៌មានបន្ថែម នៅទីណា?

**ខោនធី Los Angeles នាយកដ្ឋានសុខភាពសាធារណៈ:**
ជំងឺអុតស្វា (Monkeypox)
publichealth.lacounty.gov/acd/Monkeypox.htm

**មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)**
ជំងឺអុតស្វា (Monkeypox)
cdc.gov/poxvirus/monkeypox/index.html



COUNTY OF LOS ANGELES
Public Health

# ជំងឺអុតស្វា (Monkeypox)

## 7. តើខ្ញុំគួរធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំសង្ស័យថាខ្លួនឯងមានជំងឺអុតស្វា?

សូមទាក់ទងទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកគិតថាអ្នកមានសញ្ញា ឬរោគសញ្ញានានានៃជំងឺអុតស្វា។

## 8. តើខ្ញុំអាចធ្វើតេស្តរកជំងឺអុតស្វាដោយវិធីណា?

សូមទាក់ទងទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកគិតថាអ្នកបានឆ្លងមេរោគអុតស្វា។ សូមហៅទៅកាន់លេខ 2-1-1 ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាព ឬអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រទេ។ អ្នកក៏អាចទៅកាន់ គ្លីនិកផ្នែកសុខភាពផ្លូវភេទរបស់សុខភាពសាធារណៈ ណាមួយក៏បាន។